# កិច្ចសម្ភាសន៍របស់លោកយាយ ចាន់ ថន
ក៖ អ្នកសម្ភាសន៍ឈ្មោះហេង សុជីវី ខ៖ អ្នកត្រូវគេសម្ភាសន៍ឈ្មោះ ចាន់ ថន

ក៖ ចាសជាដំបូងជំរាបសួរលោកយាយ!
ខ៖ ចាស!
ក៖
ចាស!លោកយាយនៅក្នុងថ្ងៃនេះចៅមានឳកាសដើម្បីមកសម្ភាសដល់លោកយាយផ្ទាល់ហើយចៅបានធ្វើការស្មគ្រចិត្តរបស់ខាងសាលាBYUនៅខាងសហរដ្ឋអាមេរិក។
គំរោងសាលាមួយហ្នឹងគឺគេចង់ជួយចង់ក្រង់ពង្សប្រវត្តិរបស់ប្រជាជនខ្មែរអំពីខ្សែជីវិតនិងបទពិសោធន៍របស់គាត់អំពីពង្សសាវតារបស់គាត់ដែលគាត់បានធ្លាប់ឆ្លងកាត់ពីមុនមកពីនៅក្នុងសម័យដែលគួរអោយចាប់អារម្មណ៍មែនទែនដែលក្មេងៗនៅជំនាន់ក្រោយគេអត់បានកើតទាន់នៅក្នុងជំនាន់ពីដើមនុងនោះទេ។ចឹងយើងបានធ្វើការចង់ក្រង់មួយនិងដើម្បីកុំអោយវាបានបាត់ចឹងយើងបានចង់ជួយចង់ក្រង់អំពីប្រវត្តិពង្សសាវតារបស់ចាស់!ពីមុនដើម្បីទុកអោយដល់ក្មេងនៅជំនាន់ក្រោយមានការតភ្ជាប់គ្នាកុំអោយបាត់បង់ហើយនិងធ្វើការបាត់នូវពង្សាសាវតាររបស់គាត់
ដូចជាលោកយាយផ្ទាល់ជាមួយនិងកូនចៅជំនាន់ក្រោយអោយគេបានដឹងមួយនិងដើម្បីទុកអោយកូនចៅជំនាន់ក្រោយទៀតគេបានដឹងដែរតាមរយៈការសម្ភាសនូវពង្សប្រវត្តិរបស់លោកយាយផ្ទាល់តែម្តង។ចឹងនៅក្នុងថ្ងៃនេះចៅមានឳកាសដើម្បីមកសម្ភាសដល់លោកយាយចឹងតើលោកយាយបានអនុញ្ញាតដើម្បីអោយចៅធ្វើការថតសម្លេងនិងថតរូបរបស់លោកយាយដាក់នៅក្នុងវេបសាយដើម្បីទុកអោយកូនចៅជំនាន់ក្រោយគេអាចចូលទៅស្តាប់សម្លេងរបស់លោកយាយបានដែរឬទេ?
ខ៖ និយាយមិនកើតនោះទេកូនអើយខ្លាចនិយាយទៅគេសើច!
ចឹងនិយាយទៅវាមិនកើតនោះទេដូចជាពង្សប្រវត្តិកាលពីដើមមកចឹងមិនដឹងថាចង់និយាយអំពីអ្វី?
ក៖ លោកយាយចៅធ្វើការសួរលោកយាយដោយចៅមានសំណួរដើម្បីសួរនោះទេ។ដូចជានៅក្នុងការសម្ភាសជាដំបូងគឺនៅក្នុងថ្ងៃទី២៨ខែ៨ឆ្នាំ២០១៨ហើយចៅមានឈ្មោះថាហេងសុជីវីគឺជាអ្នកសម្ភាសហើយចុះលោកយាយវិញមានឈ្មោះអ្វីដែរ?
ខ៖ លោកយាយមានឈ្មោះថាលោកយាយ ចាន់ ថន។
ក៖ ចាសហើយលោកយាយតើលោកយាយមានអាយុប៉ុន្មានហើយឆ្នាំហ្នឹង?
ខ៖ អាយុ៦៤ឆ្នាំ។
ក៖ ចាសហើយលោកយាយកើតនៅក្នុងឆ្នាំណាដែរ?
ខ៖ អឺ!បានកើតនៅក្នុងឆ្នាំ១៩៥៤។
ក៖ ចាស!ហើយអឺលោកយាយមានបានចាំថាកើតនៅក្នុងថ្ងៃខែណា?
ខ៖ អត់បានចាំនោះទេចៅ។
ក៖ ចាស!ហើយចុះខែខ្មែររបស់យើងដូចជាខែមេឃ ពិសាខ បុស្សអឺនោះលោកយាយ?
ខ៖ អូ!ខែមើល...អត់បានចាំនោះទេចៅ។
ក៖ ចាស!ហើយលោកយាយមានស្រុកកំណើតនៅឯណាដែរ?
ខ៖ នៅឯខេត្តកំពង់ចាម។
ក៖ ហើយនៅក្នុងភូមិឃុំអ្វីទៅ?
ខ៖នៅភូមិកោះសំរោង។
ក៖ ចាស!
ខ៖ ហើយខេត្តកំពង់ចាម ស្រុកកំពង់សៀម។

កៈ
ចាសៗ!ហើយចុះលោកយាយនៅពេលសព្វថ្ងៃតើលោកយាយមានទីតាំងលំនៅនៅក្នុងវត្តសង្រ្គានស្ទឹងមានជ័យតែម្តងហំលោកយាយ?
ខៈ ចាស!នៅវត្តសង្រ្គានតាព្រហ្មស្ទឹងមានជ័យ។
កៈ តើលោកយាយមករស់នៅទីនេះយូរប៉ុន្មានដែរហើយ?
ខៈ តាំងពីឆ្នាំ២០០៤។
កៈ ចាស!ហើយមកដល់ពេលឥឡូវគឺឆ្នាំ២០១៨ហើយ។
ខៈ ចាស!
កៈ ហើយលោកយាយមានក្រុមគ្រួសារតែឬទេលោកយាយ?
ខៈ
អត់មានក្រុមគ្រួសារនោះទេលោកយាយមានតែកូន២ហើយនិងម្តាយតែមួយនុង។
កៈ ចឹង!
ខៈ ហើយបងប្អូនមានដែរប៉ុន្តែគេបាននៅបែកគ្នាណា!
នៅបែកៗគ្នាគេនៅខ្លះចឹងទៅនៅឯស្រុកចឹងទៅហើយខ្លះទៀតចឹងគេបាននៅឯភ្នំពេញចឹងទៅ! នៅបងប្អូនតែ៤នាក់នោះទេហើយស្រីៗនោះគេអស់ទៅហើយ! ។
កៈ បងប្អូនរបស់លោកយាយគេមានឈ្មោះអ្វីខ្លះដែរទៅលោកយាយ?
ខៈ អឺម!បងទី១ឈ្មោះបង ចាន់ធី ហើយរួចទៀតឈ្មោះ ចាន់ ចុល ហើយមួយទៀត ចាន់ ចូ ហើយនិងចាន់ ចនគឺខ្ញុំ។
កៈ ចឹងលោកយាយគឺជាកូនពៅ?
ខៈ ពៅ
កៈ ចាសហើយបងប្អូនរបស់លោកយាយមានស្រីប៉ុន្មាននិងប្រុសប៉ុន្មាននាក់?
ខៈ
នៅស្រីទាំង៤នាក់ប៉ុន្តែប្រុសបានស្លាប់នៅក្នុងជំនាន់ពពតអស់ទៅហើយ!ស្រី៤នាក់ប៉ុន្តែមានបានស្លាប់នៅក្នុងជំនាន់ពពតទាំង៤នាក់ព្រោះអីគ្រួបជ្រៀន។
កៈ ហឹម!ចឹងនៅសល់តែលោកយាយមួយនោះទេ។
ខៈនៅតែ៤នាក់ស្រីៗនុង។
កៈ ចឹងសព្វថ្ងៃពួកគាត់នៅឯណាដែលទៅលោកយាយ?
ខៈ
សព្វថ្ងៃបងស្រីមួយគាត់បាននៅឯខាងទួលស្លែងហើយមួយនាក់ទៀតនៅឯស្រុកមួយទៀតនៅឯកោះស្រទិន ហើយមួយទៀតគឺខ្ញុំនៅនេះហ្នឹងនៅភ្នំពេញហ្នឹង។
កៈ
ចាស!ហើយលោកយាយមានបាននៅចង់ចាំកាលពីសម័យពីមុនជាមួយនិងបងប្អូនរបស់លោកយាយតើលោកយាយមានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរឬទេ?
ខៈ បងប្អូនរបស់ខ្ញុំ!
កាលនុងខ្ញុំវានៅតូចដែរដល់ចឹងទៅបងៗគេបានរៀបការអស់ចឹងទៅខ្ញុំក៏នៅស្ទើរចឹងកាលដែលបានរស់នៅជាមួយឪពុកម្តាយនោះវាបានតិចណាស់ចឹងបាន១៧ទៅ១៨ឆ្នាំក៏ឪពុកម្តាយគាត់បានស្លាប់ចោលទៅអស់ប៉ុណ្ណឹង។
កៈ ចាស!
ខៈ ហើយបងៗ គេធំឥឡូវបានអាយុ៧០ឆ្នាំងជាងអស់ទៅហើយហ្នឹងបងទី១ណាចឹងបងទី១បានអាយុ៧៧ទៅ៧៨ឆ្នាំហើយ!
ហើយកាលពីមុនមកនុងវាដូចថាយើងនេះបាននៅតូចជាគេចឹងដូចថាវាមិនសូវដឹងឪពុកម្តាយបានលំបាកលំបិនអីនោះទេ!
ឪពុកម្តាយកាលនុងដឹងថាគាត់បានធូជាអីរបស់គាត់ដែរណា!ជីវៈភាពរបស់គាត់តែទើបបានចូលដល់ក្នុងជំនាន់ពពតនោះវាបានលំបាកណាស់ចឹងតែប៉ុណ្ណឹង។

កៈ
ចាស!ចឹងកាលនៅពីក្មេងៗតើលោកយាយមានបានចូលចិត្តលេងអ្វីជាមួយបងប្អូនលោកយាយដែរឬទេកាលដែលនៅពីកុមារភាព?
ខៈ អូ!ជាជម្មតា!កាលពីជំនាន់នុងមិនសូវជាអ្នកលេងអីនោះទេកូនអើយ!
ចឹងកាលនុងបានទៅរៀននៅថ្នាក់!កាលពីជំនាន់នុងគេបានហៅថាថ្នាក់ទី១ទី២នោះគេបានហៅថាថ្នាក់ ពិ
ការិអីចឹងណាដល់ពេលឥឡូវនេះគេបានហៅថាថ្នាក់ទី១និងទី២
ដល់ពេលមកវាជម្មតានោះទេមិនសូវជាបានលេងអីនោះទេ។
ដូចជាបងៗរបស់ខ្ញុំអីគេបានធំៗអស់បានអាយុបាន១៥ឆ្នាំអីបានមានប្តីហើយបានបែកអីអស់ទៅនៅតែខ្ញុំនុងចឹងបង!ៗគេបានធ្វើជាគ្រូទៅបង្រៀននៅឯភ្នំពេញហ្នឹងនេក!
ចឹងបានបែកគ្នាមករហូតដល់ពេលអាពតបានយកទៅវៃចោលដល់មកបានបែកគ្នារហូតមកទាល់តែដល់ក្នុងថ្ងៃហ្នឹងណា។
កៈ ហឹម!
ខៈ បងប្រុសនោះ!
បែកកាលនុងបានបែកគ្នារហូតហើយទៅខ្ញុំកាលនុងនៅតូចៗចឹងបាននៅជាមួយនិងឪពុកនិងម្តាយអត់មានសូវបានជួបបងប្អូននោះទេព្រោះអីកាលនុងខ្ញុំបាននៅវាងតូចជាគេ។
កៈ
ចឹងបងប្អូនកាលនុងគាត់!អឺ...លោកយាយមានដែរប៉ុន្តែលោកយាយអត់សូវបានចង់ចាំ?
ខៈ អត់សូវបានចង់ចាំនោះទេ។
កៈ ចាស
ខៈ
ព្រោះអីបងប្អូនគេធំៗចឹងគេបានច្រើនតែបានឡើងមករៀននៅភ្នំពេញចឹងណា
។
កៈ ចុះលោកយាយវិញកាលនុងបានរៀនបានត្រឹមកំរិតណាដែរ?
ខៈ
ខ្ញុំរៀនត្រឹមបានកាលពីសង្គមត្រឹមថ្នាក់ទី៧ណាដែលគេថាទី៧កាលពីសង្គមនុងណា។ហ្នឹងហើយបើសិនជាមកដល់ពេលឥឡូវនេះគេរាប់ពីទី១ទី២ទី៣ទី៤ទី៥ទី៦ទី៧
។ មីយ៉ាងអង់
មីយ៉ាងឌីកាលនុងណា។ហ្នឹងហើយដល់ពេលឥឡូវនេះគេបានហៅថយ។
កៈ ចាសត្រូវហើយ!
ខៈ ហ្នឹងហើយ!
កៈ
ចឹងលោកយាយកាលនុងលោកយាយបាននៅចាំសាលាដែរឬទេថាតើលោកយាយបាននៅរៀននៅឯសាលាណាដែរ?
ខៈ សាលាឃុំកោះសំរោងចឹងតែម្តង។
កៈ
ហឹម!ហើយលោកយាយកាលនុងតើលោកយាយមានបានរៀនភាសាអ្វីផ្សេងក្រៅអំពីភាសាខ្មែរដែរឬទេ?
ខៈ អត់មាននោះទេរៀនតែភាសាខ្មែរនុងតែម្តង
មានបារាំងអីបានបន្តិចបន្តួចតែអត់មាននោះទេកាលនុងបានរៀនតែខ្មែរ។
កៈ ចឹងភាសាខ្មែរកាលនុងលោកយាយអាចចេះអាចចេះសរសេរបានដែរឬទេ?
ខៈ បាន!

ក៖
លោកយាយកាលនៅពីក្មេងកាលដែលនៅពេលរៀននុងតើលោកយាយមានក្តីស្រម៉ៃថាធំឡើងចង់ធ្វើអ្វីដែរឬទេ?
ខ៖
កាលនុងកូនអើយ!ដូចថាមិនទៅដឹងឃើញអីនោះទេកាលនុងបានត្រឹមនឹកឃើញថាអោយតែចេះបានមើលអក្សរអីនិងអាចអានអីបានដាច់ទៅ
កាលនុងបានគិតគូអីបានប៉ុណ្ណឹងណា។
ក៖ ហឹម!
ខ៖ អោយបានគិតគូប៉ងប្រាថ្នាអីណា!
កាលនុងមានតែបងៗនោះទេដែលគាត់បានខំរៀនខំតែរកលុយបានធ្វើស្រែចំការជាមួយឪពុកម្តាយនុងកាលនុងដើម្បីរកលុយអោយបងបានរៀន។
ក៖ ហឹម!
ខ៖
ហើយចំណែកឯខ្លួនឯងវិញនុងកាលនុងមិនបានទៅគិតអីនោះទេគ្រាន់តែថាអោយតែបានចេះទៅហើយពេលនុងបានចឹងហើយក៏មានស្រុកកើតជាសង្គ្រាមអីចឹងទៅណាហើយចំណែកឯបងៗនុងគេសុតតែជាគ្រូកាលនៅសម័យពីដើម!
គេបានធ្វើការងារបានល្អៗណាស់មកដល់ត្រឹមតែខ្ញុំនេះវាចប់ត្រឹមសង្គ្រាមនិងតែម្តងនៅក្នុងអាយុ១៨ឆ្នាំហើយបងៗស្លាប់បែកគ្នារហូតតាំងពីនៅក្នុងជំនាន់ពពតមកមិនសូវបានមានអនុស្សាវរីយ៍បានជាមួយនិងគ្នានោះទេ។
ក៖ ចុះចំណែកឯឪពុកម្តាយរបស់លោកយាយវិញតើគាត់មានឈ្មោះអ្វីដែរ?
ខ៖ ឪពុកម្តាយគាត់មានឈ្មោះថា លោកតា អៀត ហុង ហើយម្តាយរបស់ខ្ញុំឈ្មោះឈឹម ថេន។
ក៖ ចាសហើយចុះគាត់បានកើតនៅស្រុកកំណើតនៅឯកំពង់ចាម?
ខ៖ នៅឯកំពង់ចាមនុងនៅឯកោះសំរោង ឯនុងតែម្តង។
ក៖ ចាស!
ខ៖ នឹង!
ក៖
ហើយចឹងកាលពីមុននុងតើលោកយាយមានបានដឹងអំពីជីវិតរបស់ឪពុកម្តាយរបស់លោកយាយកាលពីនៅក្មេងៗដែរឬទេ?
ខ៖ អត់បានដឹងនោះទេចៅ!អត់ដឹងនោះទេ។
ក៖
ចាស!ហើយចុះគាត់បានប្រកបមុខរបរអ្វីដើម្បីចិញ្ចឹមជីវិតនិងក្រុមគ្រួសារដែរយាយ?
ខ៖គាត់បានធ្វើចំការ! ចំការថ្នាំយើងនេះហ្នឹង!
ថ្នាំយើងនុងគ្មានទៅធ្វើអ្វីនោះទេកាលនុងមិនបានទៅធ្វើស្រែអីនោះទេមានតែទៅធ្វើចំការថ្នាំ។
ក៖ ចាស!
ខ៖ ប្រកបមុខរបកាលនុង។
ក៖ហើយចឹងលោកយាយក៏បានជួយដល់គាត់ចឹងទៅ?
ខ៖
ចាស!យើងនៅបន្ទុកជាមួយនិងគាត់នុងណាគ្មានអីការងារអ្វីធំដុំនោះទេហើយកាលនុងបានប្រឹងអោយតែបងៗបានរៀនហើយបងៗគេបានការងារហើយខ្លួនឯងគ្មានបានអ្វីនោះគេរៀនគ្រាន់តែបានមួយចេះៗនុង។
ក៖
ហើយលោកយាយកាលនុងលោកយាយបានយល់ឃើញបែបណាដែរតើឪពុកម្តាយរបស់លោកយាយគឺជាមនុស្សបែបណាដែរ?

ខ៖ ឪពុកម្ដាយរបស់ខ្ញុំល្អ! គាត់បានចិញ្ចឹមកូនបានល្អ!
អត់អីនោះទេ!ថាគាត់គឺជាមនុស្ស!...ខ្ញុំដូចថាបានកើតមកចំដូចថាឪពុកម្ដាយរបស់ខ្ញុំគាត់គឺជាអ្នកចេះធម៌គាត់ចេះដឹងហើយគាត់បានកាន់សីលកាលពីដើមនោះចឹងគាត់គឺជាមនុស្សល្អតែម្ដងមិនដែលបានទៅធ្វើបាបកូនអីនោះទេគាត់បានចិញ្ចឹមកូនគាត់គឺជាមនុស្សល្អណាស់ឪពុកម្ដាយរបស់ខ្ញុំគាត់មិនអោយលំបាកនោះទេ។
ក៖ ចាស!
ខ៖
ប៉ុន្តែគ្រាន់តែវាមិនសូវបានទំនើបអីកាលពីសម័យដើមណាកូនវាមិនដូចជាពេលឥឡូវកាលពីដើមនោះ។
ក៖
ចាស!ចឹងកាលពីសម័យដើមនុងតើឪពុកម្ដាយរបស់លោកយាយបានធ្វើការផ្ដែផ្ដាំនិងទូន្មានដល់លោកយាយដែរឬទេ?
ខ៖
អឺម!កូនអើយផ្ដែផ្ដាំនុងចេះតែបានប្រដែលប្រដៅអោយយើងបានដើរទៅតាមផ្លូវល្អ!
កូនអត់ពីឪពុកម្ដាយទៅចឹងគាត់បានចេះតែផ្ដែផ្ដាំហើយណាមួយកាលនុងយើងនេះនៅស្ទើមិនសូវដូចថាបានចេះដឹងជ្រៅជ្រះអីចឹងណាកូន
មិនសូវនោះទេដល់ចឹងកាលនុងគាត់មានអាយុបាន៧៧ហើយចឹងខ្ញុំនេះអាយុបានទើបតែ១៨គាត់បានស្លាប់ចោលទៅអស់ហើយ។
ក៖ ហឹម!
ខ៖ ស្លាប់ចោលអស់ហើយតែប៉ុណ្ណឹង។
ក៖ចឹងកាលនុងលោកយាយទើបតែមានអាយុបាន១៨ឆ្នាំ?
ខ៖
បានតែ១៨ឆ្នាំនោះទេ!ហើយគាត់មានអាយុបាន៧០ឆ្នាំជាងហើយនុងណាកូនម្ដាយក៏មានអាយុ៧០ឆ្នាំជាងហើយឪពុកក៏មានអាយុបាន៧០ឆ្នាំជាងដែរ។
ក៖
ហើយលោកយាយមានបាននៅចាំឆ្នាំកំណើតរបស់ឪពុកម្ដាយរបស់លោកយាយអត់?
ខ៖ មើល! ខ្ញុំបាននៅចាំតែឆ្នាំរបស់ម្ដាយគាត់បានកើតនៅក្នុងឆ្នាំមមី
ហើយកាលនុងគាត់បាន៧០ប៉ុន្មាននោះទេតែបានដឹងថាគាត់បានសុតតែ៧០ឆ្នាំអស់ហើយតែមិនបានដឹងថា៧០ប៉ុន្មាននោះទេតែបើសិនជាឪពុករបស់ខ្ញុំគាត់បាន៧៩ឆ្នាំ!
ម្ដាយរបស់ខ្ញុំគាត់បាន៧០ជាងដែលកាលនុងប៉ុន្តែគ្រាន់តែថាមិនបានដឹងថានៅក្នុង៧០ប៉ុន្មាននោះទេវាអត់បានច្បាស់ណា!
បើខ្ញុំនេះកាលនុងវានៅស្រិចស្រិលដែលកាលនុងបើសិនជានៅក្នុងជំនាន់ពពកយើងលែងតែបានទៅកងច្រល័តអីចឹងមិនសូវបានចាំឆ្នាំរបស់គាត់នោះទេណា!ចឹងបានដឹងតែថាគាត់បាន៧០ឆ្នាំជាងបានគាត់ស្លាប់។
ក៖
ចាស!ហើយចំណែកឯជីដូនជីតារបស់លោកយាយវិញតើកាលនុងលោកយាយបានកើតទាន់ពួកគាត់ដែរឬក៏អត់?
ខ៖ អត់!អត់ទាន់នោះទេចៅ។
ក៖ ទាំងខាងឪពុកនិងខាងម្ដាយ?
ខ៖ ចាស!ទាំងអស់អត់នៅទាន់អីនោះទេ។
ក៖
ចឹងតើលោកយាយអាចនៅចាំឈ្មោះលោកតានិងលោកយាយរបស់លោកយាយបានដែរឬទេ?

ខ៖ បើផាជីដូនអត់បានចាំនោះតែម្តង! អត់បាននៅចាំនោះទេខ្ញុំវាអត់បាននៅចាំ។
ក៖ ចាស!ហើយចឹងនៅពេលដែលក្រោយមកនៅក្នុងជំនាន់ពពតគេបានធ្វើការជំលៀសលោកយាយនិងក្រុមគ្រួសារទៅឯណាដែរ?
ខ៖ ជំលៀសខ្ញុំទៅខាងភូមិថ្មពេជ្យ! ថ្មពេជ្យនុងនៅក្នុងឃុំអ្វីនោះទេកាលនៅក្នុងជំនាន់នុងខ្ញុំវាអត់បានចាំនោះទេ! បានត្រឹមតែដឹងថានៅក្នុងភូមិថ្មពេជ្យណា។
ក៖ ចាស!
ខ៖ ហ្នឹងហើយ! ហើយវាអោយចូលទៅក្នុងព្រៃជ្រៅតែវាមិនបានដឹងថាគេបានហៅថានៅក្នុងភូមិអីគេនោះទេ! គេបានជំលៀសយើងទៅនុងចឹងយើងនេះវាមិនបានដឹងនោះទេព្រោះអីនៅក្នុងព្រៃស្ងាត់ច្រងំចឹងទៅណា! ប៉ុន្តែបានដឹងត្រឹមតែថានៅក្នុងភូមិថ្មពេជ្យ។
ក៖ ចាសលោកយាយ!
ខ៖ ហើយកាលនុងបាននៅរាងស្ទើ១៨ឆ្នាំប្រហែល១៧ទៅ១៨ឆ្នាំនុងហើយឪពុកម្តាយគាត់ចាស់!ៗបាន៧០ជាងអស់ទៅហើយបានជំលៀសទៅពី២ម្តាយនិងកូនហើយចំណែកឯបងៗគេនៅឯភ្នំពេញដែលបានបែកគ្នាតាំងពីនៅក្នុងឆ្នាំ១៩៧៥នោះ។ គេបាននៅរៀនចឹងហើយគេបានបែកគ្នាទាំងបងនិងប្អូនតាំងពីនុងមក។
ក៖ ហឹម!
ខ៖ យើងបានបែករហូត!!...តាំងពីពេលនុងមកហើយខ្ញុំនេះគេបានជំលៀសទៅជាមួយនិងឪពុកម្តាយចាស់និងខ្ញុំមួយនាក់នុង!ទៅភូមិថ្មពេជ្យនុងហើយឡើងស្ងាត់ច្រងំមិនបានដឹងថាគេបានហៅថាភូមិឃុំអីនោះទេ!។
ក៖ តើពេលនុងគេបានជំលៀសឪពុកម្តាយរបស់លោកយាយនិងលោកយាយតើគេបានអោយនៅបានជុំគ្នាដែរឬក៏អត់?
ខ៖ បាននៅជុំៗ!
ក៖ ចាស!គេបានប្រើលោកយាយនិងឪពុកម្តាយរបស់លោកយាយបានធ្វើអ្វីគេខ្លះដែរកាលនុង?
ខ៖ ម្តាយខ្ញុំកាលនុងគេបានប្រើអ្នកដែលថាចាស់!ៗនុងអោយនៅក្រង់ស្បោ! គេបានអោយទៅច្រូតស្បោនុងហើយគេបានអោយទៅច្រូតសំណាប!ចឹងទៅហើយខ្ញុំកូននេះបាននៅមានកំលាំងពេញចឹងគេបានអោយទៅកងចល័តទៅរែកដីចឹងណា!
គេបានអោយទៅរែកដីគេបានអោយទៅមុខព្រួញ!សព្វចឹងទៅ!គេបានផ្លាស់ទៅមុខព្រួញចឹងទៅណា!
ជូនកាលគេបានអោយចល័តទៅភូមិនេះទៅភូមិនោះគេបានអោយទៅស្ទូងដកទៅ!
គេដកបានមួយកងៗចឹងទៅនៅឯភូមិនេះភូមិនោះចឹងទៅណា!ហើយមានខ្លះគេបានអោយទៅរែកដីនៅឯភូមិឃុំនោះអីចឹងទៅណា!ហ្នឹងនៅក្នុងជំនាន់ពពតមានតែប៉ុណ្ណឹងក្មួយអើយ។
ក៖ ចាស!លោកយាយ!
ខ៖ ហ្នឹងហើយ!

ក៖
ហើយទៅគេមានដែលបានធ្លាប់ធ្វើបាបដល់លោកយាយដែរឬទេកាលនៅក្នុងជំនាន់នុង?
ខ៖ ខ្ញុំកាលនុងវាបានធ្វើបាបតែផ្លូវចិត្តរឿងហូបរឿងចុកអីចឹងណា! បើសិនជារឿងវ៉ៃដំច្រចែកអីអត់មាននោះទេគ្រាន់តែថារឿងបញ្ហាជីវិតនៅឯនុងវាបានស្ទើតែរស់និងងាប់នុងវាស្ទើ!ព្រោះអីកើតគ្រុនចាញ់នោះផងហើយគ្មានស្អីជាថ្នាំសង្កូវអីនោះទេថាសឹងតែកដៃបានប៉ុនៗដងវ៉ែកទំរាំតែបានរស់នោះ។
ក៖ហឹម!
ខ៖ ទំរាំបានរស់ជាមនុស្សនោះឈឺទៅបើសិនជាយើងមិនទៅគេថាយើងខ្ជិល! វាចឹងណា!ហើយយើងនេះក៏បានចេះតែតស៊ូចឹងទៅហើយបើសិនជាមានផ្លែល្ពៅអីនោះបានមួយនុងមកដុតភ្លើងអោយតែបានឆ្អិនៗចឹងទៅអោយតែមានបានពេញៗក្រពះអីចឹងទៅណាអោយតែបានផ្លែឈើអីក៏ដោយអោយតែបានហូប។
ក៖ ចឹងកាលនៅក្នុងសម័យនុងលោកយាយបានធ្លាប់ឈឺដែរលោកយាយ?
ខ៖ ឈឺ!!ឈឺ!ឡើងជ្រុះសក់អស់ហើយចៅព្រោះឈឺគ្រុនចាញ់ជ្រុះសក់នុងអស់ហើយ!!។
ក៖ ចាញ់ទឹកដីនិងមូសខាំ!។
ខ៖
ចាញ់!!ចាញ់ទឹកដីពីណាបានហូបចុកវាអត់បានគ្រាប់គ្រាន់ហើយទៅធ្វើការវាហួសកំលាំងវាគ្មានស្អីអោយបានប៉ះពៅកំលាំងនោះទេវាដូចថាវាស្ទើតែនិងងាប់និងរស់វាបាននៅស្ទើចឹងណាតែថានេះវាមានជីវិតថ្លៃវាចេះបានរស់ផុតពីអាពតចឹងទៅណាកូន។
ក៖ ចាស!
ខ៖
វាបានផុតពីអាពតចឹងទៅយើងនេះក៏បានចេញតែរស់ចឹងទៅហើយឪពុកម្តាយគាត់បានស្លាប់អស់ចឹងហើយនៅតែឯងចឹងទៅ។
ក៖
លោកយាយកាលនៅក្នុងសម័យនុងមានធ្លាប់ឃើញពពតយកមនុស្សទៅសម្លាប់ចោលនៅនិងភ្នែកដែរឬទេ?
ខ៖ មានតើកូន!!
បានមើលឃើញច្បាស់និងភ្នែកដូចថាយាយកាលនុងគេបានជំលៀសយាយទៅនៅភូមិថ្មពេជ្យនុងហើយនៅជិតនិងចំការកៅស៊ូហើយគេបានអោយយើងទៅច្រូតស្បោហើយគេបានអោយយើងនេះទៅរែកដីអីចឹងទៅហើយប៉ុន្តែបានឃើញផ្ទាល់! បានឃើញផ្ទាល់គឺរឿងដែលបានដាក់ឡាន!
បានឃើញផ្ទាល់ដែលបានដាក់ឡានគេដាក់ទៅនុងណា!
គេបានដាក់ទៅហើយចឹងសុតតែបានដាក់នៅក្រមាចឹងទៅហើយដល់ពេលល្ងាចឡើងនោះគ្មាននរណាគេបានហាមហូបបាយនោះទេកូនអោយព្រោះអីគេបានយកទៅណាយកទៅនៃនោះទេអត់បានដឹង!ចឹងហើយមួយៗអត់បានបាយអត់អីចឹងក៏គ្មានដឹងថាអត់បានបាយដែរ!។
ក៖ ហឹម!
ខ៖ ចុះកាលនុងភ័យពេកនោះ!
ភ័យអត់ហ៊ានចឹងបានថាម្លេះហើយក៏ថាទៅអោយតែបាននៅរស់មួយថ្ងៃៗចឹងទៅហើយដល់ពេលដើរទៅបានឃើញគេ!...កាលនុងមិនបានដឹងថាគេបានយកវ៉ៃមកពីខាងណានោះទេ! ដេកនៅលើដីនុងណា!
មិនបានដឹងថាពីខាងណាមកឯខាងណានោះទេឬក៏បានដូរគ្នាមកពីទិសខាងនោះទីនោះទៅឯនេះចឹងទៅណា! ។
ក៖ ហឹមលោកយាយ!
ខ៖ វាចឹងទៅតាមអង្គភាពរបស់គេ។

ក៖
ហើយលោកយាយកាលនៅក្នុងជំនាន់ពពតនុងលោកយាយបានគេងសំរាកបានប៉ុន្មានម៉ោងដែរ?
ខ៖
អឺម!ពេលល្ងាចគេបានអោយយើងបានរែកដីនុងចាំមើល!...ម៉ោង៤ក្រោកទៅរែកដីហើយនៅពេលម៉ោង៤ភ្លឺនុងនាំគ្នាក្រោកលុបមុខលុបមាត់អីទៅហើយមានបង្ហឺអីចឹងបានទៅៗបានកាប់ដីនៅម៉ោង៤ល្ងាចអីបានចូលមកវិញហើយណា!បានសំរាកក្រោកពីយប់ចឹងបានទៅទៀតចឹងបានមានម៉ោងបានប៉ុណ្ណឹង។
ក៖ ហឹម!
ខ៖ បានតែប៉ុណ្ណឹង!
ក៖
ចាស!ហើយទៅកាលនុងលោកយាយបានបន់អោយពពតឆាប់ដាច់ឆាប់ៗដែរឬទេកាលនុង?
ខ៖
អឺម!កូនអើយកាលនុងមិនបាននឹកស្មានថាគេចប់នោះទេបាននឹកស្មានថាបែបចឹងរហូតហើយមើលទៅតែចេះរួចចឹងដែលណា។
បន់ណាស់ថាបាននឹកឃើញថាវាលំបាកយ៉ាងនិងចឹងបានគិតយ៉ាងម៉េចទៅ?
មិនបានដឹងថានៅក្នុងថ្ងៃណាបានដូចកាលពីមុនវិញ។
ក៖ ហឹម!
ខ៖
ស្រាប់តែមិនបាននឹកស្មានថាបានរួចវិញដែលណាស្រាប់តែម្នាក់ៗវាសំណាងដែលបារស់នៅក្នុងសម័យពពតនុងដែលបាននៅរស់រួចជីវិតយើងនុង!
អ្នកដែលមានសំណាងហើយអ្នកដែលបានធ្វើបុណ្យល្អហើយដែលបាននៅរស់នុង។
ក៖
ចឹងនៅពេលដែលបានដាច់សម័យពពតដាច់បានសំរេចហើយតើលោកយាយកាលនុងលោកយាយបានរត់ទៅជួបជុំគ្នាជាមួយនិងឪពុកម្តាយនិងបងប្អូនរបស់លោកយាយនៅក្នុងទីតាំងនៅឯណាដែរ?
ខ៖ ខ្ញុំនៅឯស្រុកតើកូន!
ដល់ពេលស្រុកបានស្រួលចឹងគេបានអោយយើងទៅស្រុកវិញ!
ដូចថាយើងមានផ្ទះយើងកាលពីមុននៅឯកន្លែងណាចឹងគេបានអោយយើងបានមកនៅកន្លែងវិញចឹងណា។
ក៖ ចឹងបានជុំគ្នានៅទីតាំងនៅក្នុងស្រុក។
ខ៖ ហ្នឹងហើយ!បានមកជុំគ្នានៅឯក្នុងស្រុកទេសវិញចឹងទៅ។ហ្នឹងហើយ!
ក៖ ចាស!
ខ៖ មករកផ្ទះមករកសំបែងអីចឹងទៅណា!
ខ្លះទៅពេលដែលបានមករកផ្ទះចឹងផ្ទះនោះត្រូវបានគេរុះរើសធ្វើជារោងបាយអីអស់ចឹងទៅតែចំណែកខ្ញុំនេះអត់អីនោះទេផ្ទះរបស់ខ្ញុំនោះតែបើសិនជាគេវិញចឹងពេលដែលបានមកនុងគេបានរុះយកផ្ទះអស់ចឹងទៅ!ហើយគេបានធ្វើជាខ្ទមនៅអីចឹងទៅណា។
ក៖
ហើយលោកយាយកាលផ្ទះលោកយាយកាលនៅសម័យកាលពីមុននុងមានរូបរាងបែបណាដែរ?
ខ៖
ផ្ទះរបស់ខ្ញុំគឺជាផ្ទះកាលពីដើមកូនអត់មានដូចសម័យនេះនោះទេដែលកាលពីដើមនុងគេហៅថាផ្ទះ បិតណា!
ហើយផ្ទះបិតនុងវាបានតែ៣ខ្នងនោះទេតែថាវាអត់អីនោះទេកាលនៅក្នុងជំនាន់ពពតគេមិនបានរុះនោះទេវាបាននៅដល់ពេលនៅក្នុងសម័យនេះណា។

កៈ ចាសចឹងផ្ទះនេះគឺជាកេរខាងណា?
ខៈ ជាកេរខាងឪពុកម្ដាយគាត់គឺជាអ្នកដែលធ្វើ។
កៈ ចុះសម័យឥឡូវនេះផ្ទះនុងនៅឯណា?
ខៈ នៅ!នៅដដែរនោះទេផ្ទះនុងនៅឯកោះណា!បងស្រីគាត់បាននៅ!
បងស្រីដែលនៅខាងភូមិកោះសំរោងនុងណា។
កៈ ចាស!
ខៈ ហ្នឹងហើយ!
កៈ
ហើយលោកយាយជីវិតរបស់លោកយាយដែលបានឆ្លងកាត់ជីវិតតាំងពីមុនមកដល់ពេលឥឡូវនេះតើលោកយាយបានប្រកបការងារអ្វីខ្លះដើម្បីចិញ្ចឹមជីវិតដែរសំរាប់ខ្លួនឯងនិងក្រុមគ្រួសារ?
ខៈ
រាល់តែថ្ងៃនៅពេលដែលបានបែកមកពីពតមកហឹម!ជីវិតរបស់ខ្ញុំនោះបានមានក្រុមគ្រួសារហើយដល់ពេលបានមានគ្រួសារទៅបានកូន១និង២ចឹងទៅ!
គេ...កាលនុងនៅក្នុងជំនាន់ពពតនោះទេដែលគេបានរៀបការអោយយាយនោះ!
។
កៈ ហឹម!
ខៈ
គេបានរៀបការអោយដល់ទៅ៣០គូ!ដល់ចឹងហើយដល់ពេលបានរួចពីពពតចឹងមកគ្រួសារនោះមានរកស៊ីដូចថាគេបានបែកប្រាជ្ញាអីចឹងគេបានមានស្រីអីចឹងបានទៅចោលយាយចឹងទៅណាហើយចឹងទៅយាយនេះក៏!...កាលនុងយាយបានបែកគ្នាយាយនេះបានកូន២នាក់ហើយចឹងក៏បានបែកគ្នារហូត។
កៈ ចាស!
ខៈ
បែកគ្នារហូតចឹងទៅ!មកដល់ពេលឥឡូវនេះចឹងប្ដីរបស់ខ្ញុំគាត់ក៏បានស្លាប់ដែរ។
ខ្ញុំនេះក៏ចេះតែបានកាត់ខោអាវអីបានលក់ចឹងទៅបានដើម្បីចិញ្ចឹមកូន២នាក់ចឹងទៅដល់ពេលជំនាន់គេនេះដែលគេបានបើករោងចក្រនៅក្នុងទីក្រុងភ្នំពេញនេះចឹងក៏បាននឹកឃើញថាហឹម!កូនស្រីនុងបានអាយុ១៤ឆ្នាំចឹងហើយក៏បាននឹកឃើញថាមានរោងចក្រគេបានបើកចឹងក៏បានអោយកូននោះបានមកដេរអីនិងគេនិងឯងអីចឹងទៅណា!
ក៏មក២នាក់ម្ដាយនិងកូននុងទៅដោយបានមកជួលផ្ទះគេនៅឯជិតវត្តស្ទឹងមានជ័យនុងចឹងហើយពេលនុងខ្ញុំនេះបានឃើញគេសុំសីលនៅឯក្នុងវត្តស្ទឹងមានជ័យហ្នឹង!
ក៏ឃើញហឹម...បាននឹកឃើញថាមិនដឹងបានអ្វីសង្ឃឹមទៅមុខនោះទៀតនោះទេ!
ប៉ុន្តែខ្ញុំនេះហ្នឹងបានសុំសីលបានយូរណាស់ទៅហើយនៅពេលដែលខ្ញុំបាននៅតាំងពីអាយុបាន៥០ឆ្នាំខ្ញុំបានចូលទៅសុំសីលដល់ពេលបានឃើញគេបានចូលសុំសីលចឹងក៏បាននឹកឃើញថាគេបានបួសជាដូនជីកាលនុងក៏បាននឹកឃើញចឹងទៅ!
ក៏បានសុំគណៈកម្មាធិការដើម្បីបួសជាដូនជីអីចឹងបួសនៅហ្នឹងហើយក៏បានសុំលោកអោយបានមកនៅឯក្នុងវត្តនេះចឹងទៅណាតាំងពីនុងមករហូតបានមកដល់សព្វថ្ងៃនេះចឹងទៅណា។ហ្នឹងហើយតាំងពីនុងមកខ្ញុំបានបួសជាដូនជីនៅវត្តស្ទឹងមានជ័យហ្នឹងចឹងទៅ។
កៈ ចាស!
ខៈ ហើយជីវៈភាពវាមិនតែប៉ុណ្ណឹង។
កៈ
ចាស!លោកយាយហើយកាលពីមុនហ្នឹងគេបានរៀបចំអោយលោកយាយនុងកាលនុងលោកតាអត់ដែលបានស្គាល់លោកយាយហើយនិងលោកយាយក៏អត់ដែរបានស្គាល់លោកតាដែរ?

ខ៖ អត់នោះទេ! ពពតគេបានរៀបចំអោយ!
គេដូចថាគេបានអោយចាប់គូចឹងតែម្តងណាប៉ុន្តែថាកាលនៅក្នុងជំនាន់នុងខាងគ្រួសាររបស់ខ្ញុំហ្នឹងដូចថាមនុស្សវាមិនជាអាក្រក់អីប៉ុន្មានដែរដូចថាបានម៉ារល្មមសមរម្យអីចឹងដែរណាប៉ុន្តែដល់ពេល!ដល់ពេលបានបែកដែលពពតគេបានរៃបែកចឹងទៅគេនោះបានមកបែកប្រាជ្ញាចឹងទៅគេបានរកស៊ីហើយគេបានទៅមានស្រីចោលយាយនេះចឹងទៅណា
ចឹងហើយយើងបានបែកគ្នាមកតាំងពីយូរណាស់ទៅហើយ!ជាងយូរហើយតាំងពីកូន...។
ក៖ គាត់មានឈ្មោះអ្វីដែលលោកតា?
ខ៖ ឈ្មោះ តាំង ដារ៉ា ប្តីនុងស្លាប់ហើយគាត់បានស្លាប់ហើយប្តីខ្ញុំនោះ
គាត់បានម៉េមាយបានកូន២ចឹងហើយគាត់បានស្លាប់ចោយអស់ហើយ។
ក៖
ចាស!ចឹងលោកយាយកូនរបស់លោកយាយនៅពេលសព្វថ្ងៃនេះនឹងគាត់មានឈ្មោះអ្វីដែរទៅលោកយាយ?
ខ៖ កូននៅពេលសព្វថ្ងៃនេះប្រុសនឹងមានឈ្មោះថា គុលា ។
ក៖ ចាសហើយចុះម្នាក់ទៀតលោកយាយ?
ខ៖ នេះ!នៅឯទីនេះវាមានឈ្មោះថាស្រីនាង។
ក៖
កូនរបស់លោកយាយទាំង២នាក់តើពួកគាត់បានរៀនដល់កំរិតណាដែលទៅលោកយាយ?
ខ៖ នេះ! កូនប្រុសគេបានរៀនដែលគេបានរៀនដល់ថ្នាក់ឌីប្លូមដែរកូនប្រុស។
ក៖ ហឹម!
ខ៖
ហើយកូនស្រីមិនសូវបានរៀនបានប៉ុន្មាននោះទេវាបានរៀនត្រឹមថ្នាក់ទី៣និងទី៤អីនោះទេ!
គ្មានដូចថាម្តាយខ្ញុំនេះហ្នឹងវាបានចេះតែឈឺដែលនិងណាចឹងហើយជីវះភាពយើងនេះវាលំបាកដល់ចឹងហើយទៅកូនខ្ញុំវាដល់ពេលចឹងទៅបានឈប់ចឹងទៅក៏បានអោយវាបានចូលទៅដេរហ្នឹងណា! វាជាស្រីម៉ាមាយចឹងវាលំបាកណាស់កូនអើយ។
ក៖ ចាស!សូមសរសើរដល់លោកយាយមែនទែនដែលខំប្រឹងចិញ្ចឹមគ្រួសារ។
ខ៖ ចាសចឹងណា!
ក៖
ចាសហើយលោកយាយទាក់ទងជាមួយនិងជីវិតរបស់លោកយាយតាំងពីមុនមកដល់ពេលឥឡូវនេះតើលោកយាយបានគិតថាជីវិតរបស់ខ្លួនឯងមានការផ្លាស់ប្តូរអ្វីគេខ្លះដែរទៅលោកយាយ?
ខ៖ រាល់តែថ្ងៃនេះបាននឹកឃើញថាចេះ!
បានផ្លាស់ប្តូរត្រង់ថាយាយបានមកសុំសីល!
បានចូលសុំសីលធ្វើជាដូនជីនុងបាននឹកឃើញព្រះពុទ្ធព្រះធម៌នឹងព្រះសង្ឃដែលបានចិញ្ចឹមយាយហ្នឹង។
ក៖ ហឹម!
ខ៖
ដែលបានចិញ្ចឹមដល់យាយហ្នឹងចឹងអោយបានរស់រហូតបានតមក!ដែលគេបានហៅទៅបុណ្យចឹងទៅ!
គេបានជូនបច្ច័យអីចឹងទៅហ្នឹងគេបានទើបតែមកពីបុណ្យសពអីចឹងគេបានមកធ្វើបុណ្យចឹងគេបានហៅជូនបច្ច័យអីចឹងទៅ! បានហូបអីខ្លះចឹងទៅណាកូនបានប៉ុណ្ណឹង
ទើបសិនជាថាអោយបានធូធារអីនោះមិនបាននោះទេកូនអើយបានតែមួយរស់ៗ!តែប៉ុណ្ណឹងចឹងបានព្រះធម៌ជួយ។

ក៖
ចឹងលោកយាយកាលពីមុនអីតើលោកយាយបានចូលចិត្តស្ដាប់បទចម្រៀងដែរឬទេលោកយាយ?
ខ៖ ហឹមកាលដែលនៅកាលពីក្មេងនោះបានចូលចិត្តស្ដាប់ដែរ!
ប៉ុន្តែមកដល់ពេលឥឡូវនេះគឺស្ងួនឡៃតែម្ដងបានស្ដាប់តែព្រះធម៌អីចឹងទៅណា! ។
ក៖ ចុះសំរាប់ល្បែងកាលនៅពីកុមារភាពវិញ?
ខ៖ អត់ចេះនោះទេកូនអើយ!
អត់ចេះសោះ!អីក៏យាយអត់ចេះដែលអត់បានចេះនោះទេមួយបងប្អូនគ្មាននរណាគេបានចេះអីនោះទេកូនអើយអារឿងល្បែងអត់មានសោះ។
ក៖
ហើយចុះចំណែកឯឧបករណ៍ភ្លេងរបស់ខ្មែរយើងវិញតើមានអ្នកចេះលេងដែរឬទេ?
ខ៖ អត់!អត់មាននោះទេ!អត់មាននរណាគេបានចេះនោះទេ។
ក៖ ហើយចុះចំណែកឯខាងមុខម្ហូបតើលោកយាយចូលចិត្តមុខម្ហូបអ្វីដែរ?
ខ៖ អូ!បើសិនជាមុខម្ហូបវិញជាធម្មតានោះទេ!ម្ហូបខ្មែរយើង! ប្រហើរ
ម្ជូរអីជាធម្មតាមិនទៅជាទំនើបអីនិងគេនោះទេ! តែសាមាញ្ញៗ!នោះទេ។
ក៖
ចាស!ហើយលោកយាយតើនៅក្នុងជីវិតរបស់លោកយាយបានមានខ្សែជីវិតការលំបាកពីក្មេងមកដល់ពេលឥឡូវនេះដែលបានធ្វើអោយលោកយាយបានចង់ចាំមកដល់ពេលឥឡូវនេះមានអ្វីគេខ្លះទៅ?
ខ៖
ហឹម!គ្រាន់តែថាវាសំខាន់កាលដែលបានកាលពីមុនមកនោះគឺវាសំខាន់នៅក្នុងសម័យកាលពពតនោះវាលំបាកតែមួយនុងនោះទេ!
កាលពីជំនាន់មុននុងថាអោយ
បានលំបាកពីឪពុកនិងម្ដាយមកនុងមិនបានលំបាកនោះទេមកត្រឹមពីអាយុរបស់យើងបាន១៥មកដល់១៨ឆ្នាំនុងបានមានលំបាក!វាមានតែការស្រុកយើងបានកើតសង្គ្រាមអីចឹងណា!
កាលនៅក្នុងជំនាន់ពពតនុងវាលំបាកតែមែនទែនតែម្ដងវាមានតែប៉ុណ្ណឹងដល់ពេលបានរួចមកបានមានប្ដីនិងប្រពន្ធឆាកជីវិតរបស់យើងក៏បានតស៊ូដោយខ្លួនឯងចឹងទៅណា!
កាលរស់នៅតែបានឬក៏មិនបាននោះក៏វាបានតែប៉ុណ្ណឹងនោះទេ!
កាលនៅពីជំនាន់នោះសម័យពពតបានស៊ីបានរួមគ្នាឆ្នាំងរួមមែនតែវាបានពិបាកចិត្តណាស់កូន វាចឹងណា។
ក៖
ចឹងលោកយាយកាលដែលលោកយាយពិបាកចិត្តម្ដងៗតើលោកយាយតែងតែធ្វើអ្វីដែលដើម្បីបំបាញ់ការពិបាកចិត្តឬក៏បានធ្វើអោយអារម្មណ៍របស់លោកយាយស្រួលជាងមុនចឹងណា?
ខ៖
ហឹម!មិនបានដឹងថាត្រូវធ្វើម៉េចនោះទេចៅអើយព្រោះអីកាលនៅពីជំនាន់ពពតនោះ!
យើងមិនបានទៅសប្បាយអីនោះទេបើសិនជាយើងបាននិយាយទៅវាខ្លាចខុស!
ចឹងចង់សប្បាយក៏សប្បាយវាមិនកើតដល់ពេលមកសម័យនេះបានគ្រាន់ថាយើងបានផ្លូវធម៌បានអប់រំចិត្តបានអោយអារម្មណ៍របស់យើងនេះវបានល្អចឹងទៅណាចៅ។
ក៖ ហឹម!
ខ៖ វាអត់មានអីពិបាកជាងរកផ្លូវធម៌នោះទេ!។
ក៖ ចាស!

ខ៖
អារឿងដែលយើងមកដល់ពេលវ័យនេះហើយគ្មានថាអោយយើងមានពេលទៅដើរលេងស្តាប់ភ្លេងអីវាហួសទៅហើយ។
ក៖ ចាសត្រូវហើយលោកយាយ!
ខ៖ ចឹងមានតែរកផ្លូវធម៌ហើយនិងមកធ្វើតែអំពើល្អតែប៉ុណ្ណឹងចឹងទៅណា។
ក៖ ចាស!
ខ៖ ហ្នឹងហើយនិងមានការសុំសីលអីចឹងទៅ។
ក៖ហើយចុះសំរាប់រឿងល្អៗនៅក្នុងជីវិតរបស់លោកយាយវិញតើមានដែរឬទេ? ដូចថាលោកយាយបានធ្លាប់បានជួបនិងរឿងល្អៗដែលបានធ្វើអោយលោកយាយបានសប្បាយចិត្តដែរឬទេ?
ខ៖ អឺម!អានុងដូចថាពេលកូនវាបាននៅតូច!ៗ
ចឹងរឿងដូចថានៅក្នុងមួយជីវិតរបស់យាយបាននៅជាមួយនិងឪពុកម្តាយបានសប្បាយតែជាមួយនឹងឪពុកម្តាយដល់ពេលបានមានប្តីមានកូនមានអីចឹងមក! យាយលំបាកមករហូតក្អួយអើយគ្មាន!
គ្មានកន្លែងណាដែលបានទឹកឃើញមកថាអោយយាយបានស្រណុកនោះទេ! ទើបតែមកដល់ពេលយាយបានមកចូលសុំសីលនេះទេនេះដែលបានសប្បាយចិត្តនិងព្រះធម៌ណាកូន។
ក៖ ចាស!
ខ៖ មានតែប៉ុណ្ណឹង!
ក៖
ចាស!ចឹងលោកយាយតើបំណងប្រាថ្នារបស់លោកយាយតើលោកយាយចង់បានអ្វីដែរទៅលោកយាយ?
ខ៖ យាយហេសមិនចង់បានអីនោះទេកូន!
ចង់បានតែជីវិតរស់នៅតែប៉ុណ្ណឹងវាបានតែមួយល្មមនោះទេតែបើសិនជាយើងស្រែថាវាពិបាកអោយគេជួយនោះមិនបានដឹងថាទៅពឹងពីណាអោយគេជួយយើងមិនបានដឹងទៅធ្វើយ៉ាងម៉េចទៅតាមផ្លូវឯណាចឹងបានទឹកឃើញថាហឹម!ទៅខាងអង្គការនេះហឹម!ទៅខាងអង្គការនោះជួយយាយនេះមិនបានជាដឹងថាអោយទៅទាក់ទងទៅតាមផ្លូវឯណាអោយបានដល់ចឹងហើយក៏យាយបាននៅរស់នៅទៅតាមសមាជីវោរបស់លោកតាមរបៀបជាដូនជីចឹងទៅណា! ។
ក៖ ចាស!
ខ៖ មានតែប៉ុណ្ណឹង។
ក៖
ចាសចឹងជាចុងក្រោយលោកយាយមានពាក្យពេចន៍អ្វីដើម្បីផ្តែផ្តាំដល់កូនចៅជំនាន់ក្រោយ?
ខ៖
អឹម!ដល់កូនចៅជំនាន់ក្រោយយាយបានសូមជូនផ្តែផ្តាំអោយកូនចៅជំនាន់ក្រោយកុំអោយដើរទៅតាមផ្លូវខុសចឹងត្រូវដើរទៅតាមផ្លូវត្រូវធ្វើអំពីល្អកាន់ចិត្តទៀតត្រង់កុំអោយដើរទៅតាមផ្លូវខុសមានគ្រឿងញៀនគ្រឿអីនុងដែលបានធ្វើបាបដល់ឪពុកម្តាយត្រូវចេះរក្សាបងប្អូនអីនុងអ្នកជិតខាងអីនុងអោយបានចេះស្រលាញ់គ្នា។ចឹងប៉ុណ្ណឹងហើយកូនំ?
ក៖
ចាស!ចឹងលោកយាយបើសិនជាខាងសាលាគេបានចង់ដាក់សម្លេងរបស់លោកយាយនៅក្នុងវេបសាយរបស់ខាងសាលាតើលោកយាយអនុញ្ញាតដើម្បីអោយគេបានដាក់ដែរឬទេ?
ខ៖ អត់អីនោះទេកូន! ដាក់ចុះ។
ក៖ ចាស!។